**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០០៣ ០៩.១៦ អ.ក.អ.ប.

# សេចក្តីប្រកាសព័ត៌មាន

កិច្ចប្រជុំលើកទី១ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានរៀបចំឡើងនៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីពិនិត្យ និងអនុម័តលើរបៀបវារៈសំខាន់ៗនានា រួមមាន និមិត្តសញ្ញានៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រចនាសម្ព័ន្ធនិងការបង្កើតអង្គភាពចំណុះ បទបញ្ជាផ្ទៃក្នុង កម្មវិធីយុទ្ធសាស្ត្រអាទិភាព និងការពិនិត្យលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថាន និងក្រមបរិស្ថាន ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាទាំងអស់ ដែលជាមន្ត្រីជាន់ខ្ពស់តំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន៦១រូប។

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានស្វាគមន៍ចំពោះសមាជិក សមាជិកាទាំងអស់ ដោយបានចាត់ទុកកំណែទម្រង់ស្ថាប័នដែលនាំឱ្យមានការបង្កើតក្រុមប្រឹក្សានេះកាលពីខែឧសភា ឆ្នាំ២០១៥ ក្នុងនាមជាស្ថាប័នរៀបចំគោលនយោបាយ ថាជាជំហានដ៏សំខាន់មួយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅធានាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌របស់ប្រទេសជាតិ និងបានគូសបញ្ជាក់អំពីអាទិភាពចំពោះមុខសំខាន់ៗដែលក្រុមប្រឹក្សានេះត្រូវយកចិត្តទុកដាក់ និងពិភាក្សានៅក្នុងកិច្ចប្រជុំនេះ។ ឯកឧត្តមក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរវិស័យ និងការសម្របសម្រួលរវាងភាគីពាក់ព័ន្ធទាំងអស់ ដែលជាកត្តាចាំបាច់ ធានាបាននូវប្រសិទ្ធភាពការងារ និងភាពជោគជ័យរបស់ក្រុមប្រឹក្សានេះ។ ឯកឧត្តមប្រធានអង្គប្រជុំបានអំពាវនាវឱ្យសមាជិក សមាជិកាទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្តល់ការគាំទ្រពេញទំហឹង និងចូលរួមយ៉ាងសកម្មក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកធានានូវការអភិវឌ្ឍដោយចីរភាពរបស់កម្ពុជា។

អង្គប្រជុំបានប្រព្រឹត្តទៅដោយមានកិច្ចពិភាក្សាយ៉ាងសកម្ម លើរបៀបវារៈសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះនៃដំណើរការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនាពេលអនាគត សំដៅធានាឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។ លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំ រួមមាន ៖

- ការអនុម័តទៅលើរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា ដោយនឹងត្រូវមានអង្គប្រឹក្សាយោបល់ថ្នាក់ជាតិចំនួនពីរ គឺក្រុមឧត្តមមន្ត្រី និងគណៈកម្មាធិការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ, និងការបង្កើតក្រុមការងារថ្នាក់រាជធានីខេត្តដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត សំដៅធានាបាននូវការចូលរួមយ៉ាងសកម្មពីមន្ទីរពាក់ព័ន្ធជុំវិញខេត្តក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បន្ថែមពីលើរចនាសម្ព័ន្ធនេះ ក្រុមការងារបច្ចេកទេសចំនួន៧ នឹងត្រូវបានបង្កើត ដើម្បីសម្របសម្រួល និងគាំទ្រដល់ការរៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តិ លើកកម្ពស់ការស្រាវជ្រាវ អប់រំ និងបណ្តុះបណ្តាល ផ្លាស់ប្តូរបច្ចេកវិទ្យានិងនវានុវត្តន៍ ព្រមទាំងផ្សព្វផ្សាយលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។ ក្រុមបច្ចេកទេសទាំងនេះ នឹងផ្តោតសំខាន់លើ ៖ ការប្រែប្រួលអាកាសធាតុ, ទីក្រុងនិរន្តរភាព,

ថាមពលនិរន្តរភាព, ការប្រើប្រាស់ និងផលិតកម្មនិរន្តរភាព, ជីវៈចម្រុះ ការប្រើប្រាស់និងការបែងចែកផលពីធនធានពន្ធុ និងជីវសុវត្ថិភាព, វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, និងថាមពលនុយក្លេអ៊ែរ

- ការពិនិត្យនិងពិភាក្សាទៅលើនិមិត្តសញ្ញា និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ការកំណត់សកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១៦-២០១៨ មានជាអាទិ៍ ការងារទីក្រុងនិរន្តរភាព ថាមពលនិរន្តរភាព ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កិច្ចអភិរក្សជីវៈចម្រុះ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបៃតង ការរៀបចំបញ្ចប់នូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថាន និងក្រមបរិស្ថាន។

សមាជិកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក៏បានពិនិត្យលើវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថាន និងក្រមបរិស្ថាន ព្រមទាំងបានផ្តល់ធាតុចូលមួយចំនួនផងដែរ។

គួរបញ្ជាក់ផងដែរថាក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គឺជាការរួមបញ្ចូលគ្នានៃស្ថាប័នអន្តរក្រសួងដែលធ្លាប់មានចំនួន៤ គឺ ៖ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គណៈកម្មាធិការជាតិជីវសុវត្ថិភាព និងគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ។ កិច្ចប្រជុំលើកទី១នេះ ជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការពង្រឹងនូវគ្រឹះសម្រាប់ទ្រទ្រង់ការអនុវត្តកំណែទម្រង់របស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងការអភិវឌ្ឍដោយចីរភាព។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

*ព័ត៌មានបន្ថែម សូមទាក់ទង :*
ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ទូរស័ព្ទ៖ +855 12 915 351
អ៊ីម៉ែល៖ etap@online.com.kh